**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០៨-០៨៤ ប្រក

លិខិតចូល
ថ្ងៃទី ១៧ ខែ ០៧ ឆ្នាំ 2008

# ប្រកាស
## ស្តីពី
## ភតិសន្យាហិរញ្ញវត្ថុ

**ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជាជាថ្មី មានឋានៈស្មើ ទេសរដ្ឋមន្ត្រី
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨

## ស ម្រេ ច

**ប្រការ ១.-**

អនុញ្ញាតឱ្យធនាគារពាណិជ្ជ និងធនាគារឯកទេស តទៅនេះហៅថា " ធនាគារ " ធ្វើប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ដែលត្រូវបានចាត់ទុកថាជាប្រតិបត្តិការធនាគារ ស្របតាមខ្លឹមសារនៃមាត្រា ២ កថាខ័ណ្ឌ ១ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ។

**ប្រការ ២.-**

ធនាគារត្រូវមានគោលនយោបាយនិងនីតិវិធីសំរាប់ធ្វើប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ប្រព័ន្ធប្រតិបត្តិការ ប្រព័ន្ធគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង សមស្រប ។

**ប្រការ ៣.-**

ពាក្យបច្ចេកទេសដែលប្រើក្នុងប្រកាសនេះ មាននិយមន័យដូចតទៅ :

- **ភតិបតី** សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលផ្ទេរសិទ្ធិកាន់កាប់ និងសិទ្ធិប្រើប្រាស់ចលនវត្ថុទៅឱ្យភតិកៈ ។

- **ភតិក:** សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលទទួលសិទ្ធិកាន់កាប់ និងសិទ្ធិប្រើប្រាស់ចលនវត្ថុពីភតិបតី ។
- **ចលនវត្ថុ** សំដៅដល់ទ្រព្យសម្បត្តិ គ្រឿងចក្រ និងឧបករណ៍ទាំងអស់ លើកលែងតែ ដី និងអគារ ។
- **រយៈពេល** សំដៅដល់រយៈពេលដែលមានចែងក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ដែលក្នុងរយៈពេលនោះ ភតិក:ត្រូវបានអនុញ្ញាតឱ្យកាន់កាប់ និងប្រើប្រាស់ចលនវត្ថុដែលបានជួល ។
- **ភតិសន្យា** សំដៅដល់ប្រតិបត្តិការដែលភតិបតីចុះកិច្ចព្រមព្រៀងជាមួយភតិក: ក្នុងនោះភតិក:ត្រូវបានផ្តល់សិទ្ធិឱ្យកាន់កាប់ និងប្រើប្រាស់ចលនវត្ថុក្នុងរយៈពេលមួយដោយការបង់ថ្លៃឈ្នួលតាមគ្រា ឬ តាមតម្លៃសមមូល ។ ភតិសន្យាត្រូវរួមបញ្ចូលទាំងភតិសន្យាបន្តផងដែរ ។
- **ភតិសន្យាបន្ត** សំដៅដល់ប្រតិបត្តិការដែលទ្រព្យសម្បត្តិបានជួលដោយភតិក:ដំបូង ត្រូវបានជួលបន្តឱ្យភាគីផ្សេងទៀត ហើយកិច្ចព្រមព្រៀងភតិសន្យារវាងគូភាគីដំបូងនៅមានសុពលភាពដដែល ។
- **ភតិសន្យាហិរញ្ញវត្ថុ** សំដៅដល់ភតិសន្យាសម្រាប់រយៈពេលដំបូងមួយឆ្នាំ ឬ ច្រើនជាង ដែលរយៈពេលនោះមិនអាចកែប្រែបាន ក្នុងនោះ :
  ក- ភតិក:បញ្ជាក់ច្បាស់លាស់នូវចលនវត្ថុ និងជ្រើសរើសអ្នកផ្គត់ផ្គង់ ដោយមិនផ្អែកសំខាន់លើជំនាញ និងការវិនិច្ឆ័យរបស់ភតិបតីឡើយ
  ខ- ភតិបតីទិញចលនវត្ថុតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ដើម្បីជួលឱ្យភតិក: ។

  ក៏ប៉ុន្តែ បើមានការជួលបន្តនូវចលនវត្ថុដែលបានជួលពីមុនពីភតិបតីដដែល ការជួលបន្តនោះអាចនៅតែជាភតិសន្យាហិរញ្ញវត្ថុដដែល ។

  ភតិសន្យាអាចជាភតិសន្យាហិរញ្ញវត្ថុ ដោយមិនគិតដល់ :
  ក- ការបង់ថ្លៃឈ្នួលភតិសន្យាត្រូវបាន ឬ មិនត្រូវបានគណនាបញ្ចូលនូវការរំលស់ទាំងមូល ឬ ការរំលស់មួយផ្នែកធំនៃតម្លៃចលនវត្ថុ ឬ
  ខ- ភតិក:មាន ឬ ពុំមានជម្រើស ឬ ក្រោយមកទទួលយកជម្រើសថាទិញ ឬ បន្តជួលចលនវត្ថុមួយរយៈពេលបន្ថែមទៀត ។
- **ការបង់ថ្លៃឈ្នួលជាមុន** សំដៅដល់ចំនួននៃការបង់ថ្លៃឈ្នួលតាមគ្រាដោយភតិក: នៅពេល ឬ មុនពេលចាប់ផ្តើមជួល ។ ការបង់ថ្លៃឈ្នួលជាមុន មិនមែនជាប្រាក់ប្រាតិភោគទេ ។
- **ប្រាក់ប្រាតិភោគ** សំដៅដល់ចំនួនប្រាក់ដែលត្រូវបានបង់ដោយភតិក: និងត្រូវបានកាន់កាប់ដោយ

ភតិបតី ដើម្បីធានាកាតព្វកិច្ច សម្រាប់ឱ្យភតិកៈអនុវត្តតាមភតិសន្យាហិរញ្ញវត្ថុ ដោយពេញលេញ និងទៀងទាត់។

- **អ្នកផ្គត់ផ្គង់** សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលភតិបតីទទួលចលនវត្ថុដែលត្រូវជួលឱ្យភតិកៈ។ លទ្ធកម្មរបស់ភតិបតីអាចប្រព្រឹត្តទៅតាមរយៈការទិញ ការជួល ការប្រគល់សិទ្ធិឱ្យទិញ ឬ ឱ្យជួល រួមទាំងការប្រគល់សិទ្ធិពីភតិកៈផងដែរ។ នៅក្នុងប្រតិបត្តិការលក់ហើយជួលមកវិញ ភតិកៈអាចជាអ្នកផ្គត់ផ្គង់។
- **កិច្ចព្រមព្រៀងផ្គត់ផ្គង់** សំដៅដល់កិច្ចព្រមព្រៀងដែលភតិបតីទិញចលនវត្ថុដែលត្រូវជួលឱ្យភតិកៈ។
- **កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ** សំដៅដល់កិច្ចព្រមព្រៀងដែលភតិបតីទិញចលនវត្ថុដែលភតិកៈបានជ្រើសរើសពីអ្នកផ្គត់ផ្គង់ ហើយជួលចលនវត្ថុនេះទៅឱ្យភតិកៈ និងអនុញ្ញាតឱ្យភតិកៈបង់ថ្លៃឈ្នួលតាមកាលកំណត់។

**ប្រការ ៤.-**

ភតិសន្យាហិរញ្ញវត្ថុណា ដែលមិនបានបំពេញតាមនិយមន័យដែលមានចែងនៅក្នុងប្រការ ៣ នៃប្រកាសនេះ ត្រូវបានចាត់ថាជាការជួល ការទទួលជួលធម្មតា ឬ ភតិសន្យាប្រតិបត្តិការ ដែលមិនស្ថិតនៅក្រោមនិយមន័យនៃប្រតិបត្តិការធនាគារទេ។

**ប្រការ ៥.-**

ធនាគារត្រូវបានអនុញ្ញាតឱ្យធ្វើភតិសន្យាគ្រប់ប្រភេទ រួមមាន ភតិសន្យាហិរញ្ញវត្ថុ និង ភតិសន្យាប្រតិបត្តិការ រីឯគ្រឹះស្ថានមិនមែនធនាគារត្រូវបានហាមឃាត់ចំពោះការធ្វើប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុជាមុខរបរប្រក្រតី។

**ប្រការ ៦.-**

ធនាគារដែលមានបំណងធ្វើប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ត្រូវ :

ក- មានស្ថានភាពហិរញ្ញវត្ថុ និងដំណើរការប្រតិបត្តិការល្អ មានអនុបាតសាធនភាព និង អនុបាតហិរញ្ញវត្ថុផ្សេងទៀតស្របតាមបញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា

ខ- មានផែនការអាជីវកម្មជាលាយលក្សណ៍អក្សរស្តីពីភតិសន្យាហិរញ្ញវត្ថុ ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ធនាគារ។ ផែនការអាជីវកម្មនេះ ត្រូវមានខ្លឹមសារដូចខាងក្រោម :

១- គោលនយោបាយ និងនីតិវិធីនៃប្រតិបត្តិការអាជីវកម្ម

២- ព័ត៌មានលំអិតអំពីប្រព័ន្ធគ្រប់គ្រងហានិភ័យ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងប្រព័ន្ធគណនេយ្យ។

ព័ត៌មានលំអិតអំពីប្រព័ន្ធគ្រប់គ្រងហានិភ័យរួមមាន :

- ប្រព័ន្ធវិភាគឥណទាន នីតិវិធីនៃការកំណត់ពិដានឥណទានរបស់អតិថិជន នីតិវិធីនៃការកំណត់ប្រាក់ប្រាតិភោគ និងសោហ៊ុយផ្សេងៗ
- នីតិវិធីនៃការគ្រប់គ្រងចលនវត្ថុ រួមបញ្ចូលទាំងការទិញចលនវត្ថុ ការគ្រប់គ្រងចលនវត្ថុដែលបានរឹបអូស ការតាមដាន ការត្រួតពិនិត្យ ការវាយតម្លៃចលនវត្ថុ និងតម្លៃដក់សល់ ។

គ- មានការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៧.-**

ធនាគារត្រូវរៀបចំកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុជាលាយលក្សណ៍អក្សរជាមួយនឹងអតិថិជនរបស់ខ្លួន ដែលគ្រប់ភាគីពាក់ព័ន្ធទាំងអស់ត្រូវព្រមព្រៀងគោរពតាមខ្លឹមសារ និងលក្ខខណ្ឌដែលមានចែងនៅក្នុងប្រកាសនេះ ។ កិច្ចព្រមព្រៀងនេះត្រូវធ្វើឡើងយ៉ាងហោចណាស់ចំនួន ២ ច្បាប់ ដែលក្នុងនោះមួយច្បាប់ត្រូវប្រគល់ទៅឱ្យភតិកៈ ។ នៅក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ត្រូវមានចែងចំណុចសំខាន់ៗយ៉ាងតិចដូចខាងក្រោម :

ក- ការពណ៌នាពីចលនវត្ថុដែលបានជួល

ខ- ចំនួនប្រាក់ ការកំណត់គ្រា និងរយៈពេលនៃការបង់ថ្លៃឈ្នួល

គ- កាលបរិច្ឆេទចាប់ផ្តើមភតិសន្យាហិរញ្ញវត្ថុ និង

ឃ- ហត្ថលេខារបស់ភតិបតី ភតិកៈ ។

**ប្រការ ៨.-**

ក្នុងករណីកិច្ចព្រមព្រៀងត្រូវបានបញ្ចប់ និងចលនវត្ថុត្រូវបានរឹបអូសពីភតិកៈ ធនាគារត្រូវលក់ ឬ ធ្វើភតិសន្យាបន្តចលនវត្ថុនោះក្នុងរយៈពេល ៣ខែយ៉ាងយូរ ចាប់ពីថ្ងៃបញ្ចប់កិច្ចព្រមព្រៀង ឬថ្ងៃរឹបអូស ។ ក្នុងករណីអនុវត្តមិនបាន ធនាគារត្រូវធ្វើចំណាត់ថ្នាក់ និងសវិធានធនលើចលនវត្ថុនោះស្របតាមប្រកាសស្តីពី ការធ្វើចំណាត់ថ្នាក់ និងសវិធានធនលើឥណទាន និងបុរេប្រទានរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ។

**ប្រការ ៩.-**

នៅក្នុង និងក្រោយរយៈពេលនៃភតិសន្យាហិរញ្ញវត្ថុ ភតិបតីនៅតែជាម្ចាស់កម្មសិទ្ធិលើចលនវត្ថុដែលបានជួល លើកលែងតែកម្មសិទ្ធិត្រូវបានផ្ទេរទៅឱ្យភតិកៈ ឬ ទៅឱ្យភាគីផ្សេងទៀត ។

ភតិបតីមានសិទ្ធិ និងកាតព្វកិច្ចដូចខាងក្រោម :

ក- ត្រូវទទួលខុសត្រូវបង់ពន្ធនាំចូល និងកាតព្វកិច្ចសារពើពន្ធតាមច្បាប់កំណត់ និងសោហ៊ុយចុះបញ្ជីលើចលនវត្ថុដែលបានជួល លើកលែងតែកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមានចែងផ្សេងពីនេះ

ខ- ត្រូវទូទាត់សងថ្លៃទិញចលនវត្ថុទៅឱ្យអ្នកផ្គត់ផ្គង់ នៅពេលដែលភតិកៈបានយល់ព្រម

ទទួលចលនវត្ថុនោះដោយគ្មានលក្ខខណ្ឌ

គ- ត្រូវធានាយ៉ាងណាឱ្យភតិកៈបានប្រើប្រាស់ និងកាន់កាប់ចលនវត្ថុដែលបានជួល ដោយគ្មានការរំខាននៅក្នុងរយៈពេលអនុវត្តភតិសន្យាហិរញ្ញវត្ថុ ដរាបណា ភតិកៈអនុវត្តតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ

ឃ- មិនទទួលខុសត្រូវចំពោះភតិកៈលើចលនវត្ថុឡើយ លើកលែងតែក្នុងករណីដែលភតិកៈបានទទួលរងការខាតបង់ដោយសារការធ្វើអន្តរាគមន៍របស់ភតិបតី ក្នុងការជ្រើសរើស ឬក្នុងការកំណត់យថាប្រភេទនៃចលនវត្ថុ

ង- ក្នុងរយៈពេលនៃការអនុវត្តកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ភតិបតីមិនទទួលខុសត្រូវសងការខូចខាតដែលបង្កដល់តតិយជន ដោយសារកំហុសរបស់ភតិកៈ ក្នុងការប្រើប្រាស់ចលនវត្ថុដែលខ្លួនបានជួលឡើយ

ច- ក្នុងករណីដែលភតិកៈមិនគោរពតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ភតិបតីត្រូវមានសិទ្ធិបន្ថែមពីលើសិទ្ធិដែលមានចែងក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ដូចតទៅ ÷

១- អាចទាមទារឱ្យភតិកៈបង់ថ្លៃឈ្នួលដែលមិនទាន់បានសង រួមទាំងការប្រាក់ និងការខូចខាត

២- ក៏អាចទាមទារឱ្យពន្លឿនការបង់ថ្លៃឈ្នួលអនាគត អាចរំលាយកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ និងអាចទាមទារយកចលនវត្ថុដែលបានជួលមកវិញ ប្រើមានករណីណាមួយដូចខាងក្រោម ÷

- ភតិកៈមិនបានបង់ថ្លៃឈ្នួលតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុក្នុងរយៈពេលពីរគ្រាជាបន្តបន្ទាប់
- ភតិកៈបំពានខណាមួយផ្សេងទៀតនៃកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ និងខកខានមិនបានដោះស្រាយបញ្ហាក្នុងរយៈពេលដប់ (១០) ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងជាលាយលក្សណ៍អក្សរពីភតិបតី
- ភតិកៈមានអ្នកធានាដែលមានអសាធនភាព ក្ស័យធន ឬ ត្រូវបានរំលាយ ហើយភតិកៈមិនបានរកអ្នកធានាជំនួសណាម្នាក់ដែលភតិបតីអាចទទួលយកបានក្នុងរយៈពេលសាមសិប (៣០) ថ្ងៃតាមការស្នើសុំឱ្យរកអ្នកធានាជំនួសជាលាយលក្សណ៍អក្សរពីភតិបតី ឬ
- ភតិកៈមានអសាធនភាព ក្ស័យធន ត្រូវបានរំលាយ ឬ ទទួលមរណភាព ហើយពុំមានអ្នកស្នងបន្ត ។

៣- ទោះបីជាកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុត្រូវបាន ឬ មិនត្រូវបានរំលាយ នៅមុនពេលផុតរយៈពេលក៏ដោយ ភតិបតីអាច ÷

- ទាមទារយកចលនវត្ថុដែលបានជួលមកកាន់កាប់វិញ ដោយមិនចាំបាច់ប្ដឹងទៅតុលាការ ប្រសិនបើការទាមទារនោះធ្វើឡើងដោយគ្មានអំពើហិង្សា និង
- ទាមទារសំណងការខូចខាត ដែលភតិបតីត្រូវទទួលបាន រាប់ទាំងចំណាយបន្ថែមបណ្ដាលមកពីកំហុសរបស់ភតិកៈផង។ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុអាចចែងអំពីវិធីគណនាការខូចខាត ហើយវិធីគណនានេះអាចអនុវត្តបានដោយភាគីទាំងពីរ លើកលែងតែវិធីគណនានេះបណ្ដាលឱ្យមានវិការៈធ្ងន់ធ្ងរលើសពីសំណងការខូចខាត ដែលភតិបតីអាចនឹងទទួលបាន ប្រសិនបើភតិកៈអនុវត្តតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ។

៤- បើចាំបាច់ ភតិបតីអាចដាក់ពាក្យស្នើសុំដីកាសម្រេចពីតុលាការឱ្យភតិកៈប្រគល់ចលនវត្ថុជួលនោះមកភតិបតីវិញ ដោយភ្ជាប់ជាមួយនូវរាល់ឯកសារភស្ដុតាងដែលបង្ហាញថា ភតិកៈមិនបានគោរពតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ។ ប៉ុន្តែភតិបតីនៅតែត្រូវទទួលខុសត្រូវចំពោះការខូចខាតទាំងឡាយដែលកើតឡើងដល់ភតិកៈ បើនៅពេលក្រោយមកមានភស្ដុតាងបង្ហាញថា ការទាមទារចលនវត្ថុដែលបានជួលមកវិញដោយភតិបតីនោះ ជាការរំលោភលើកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ

ឆ- មានសិទ្ធិតម្រូវឱ្យភតិកៈសងការខាតបង់បំណុល ការខូចខាត ឬ ផលវិបាកផ្សេងៗណាមួយ ឬ ទាំងអស់ដែលកើតឡើងពី ឬ ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ និងការកាន់កាប់របស់ភតិកៈលើចលនវត្ថុដែលបានជួល

ជ- អាចទាមទារឱ្យភតិកៈទិញ និងបង់ថ្លៃធានារ៉ាប់រងលើចលនវត្ថុ ដែលបានជួលនៅគ្រប់អំឡុងពេលដែលភតិកៈកាន់កាប់ ឬ គ្រប់គ្រងចលនវត្ថុនោះ ទោះបីជារយៈពេលអនុវត្តភតិសន្យាហិរញ្ញវត្ថុបានឈានដល់ទីបញ្ចប់ហើយ ឬ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុត្រូវបានរំលាយមុនពេលក៏ដោយ រហូតដល់ពេលដែលចលនវត្ថុនោះត្រូវបានប្រគល់ឱ្យភតិបតីកាន់កាប់ និងគ្រប់គ្រងវិញ ។ ប្រសិនបើភតិកៈត្រូវទិញ នឹងបង់ថ្លៃធានារ៉ាប់រងហើយបែរជាខកខានទៅវិញ ភតិបតីមានសិទ្ធិទិញ តែមិនមានភារកិច្ចត្រូវទិញធានារ៉ាប់រងនេះទេ ហើយភតិកៈត្រូវសងរាល់ការចំណាយទៅឱ្យភតិបតីវិញភ្លាម ប្រសិនបើភតិបតីបានចំណាយរួចហើយ

ឈ- ចលនវត្ថុដែលបានជួលមិនមែនជាចំណែកនៃទ្រព្យសម្បត្តិរបស់ភតិកៈទេ ។ ក្នុងន័យនេះ នៅពេលដែលភតិកៈក្ស័យធន ម្ចាស់បំណុលទាំងឡាយលើភតិកៈ រួមទាំងម្ចាស់បំណុលដែលបានទទួលសិទ្ធិរឹបអូសទ្រព្យសម្បត្តិភតិកៈតាមសេចក្ដីសំរេចរបស់តុលាការផង គ្មានសិទ្ធិទាមទារយកចលនវត្ថុដែលបានជួលនោះទេ

៧- ភតិបតីអាចចាត់ចែង ផ្ទេរ ឬ ម៉្យាងទៀតបែងចែកសិទ្ធិទាំងអស់ ឬ សិទ្ធិណាមួយរបស់ខ្លួនលើចលនវត្ថុដែលបានជួល ឬ តាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុទៅឱ្យភាគីណាមួយ ដោយមិនចាំបាច់មានការយល់ព្រមពីភតិកៈ ។ ការផ្ទេរបែបនេះមិនត្រូវធ្វើឱ្យភតិបតីរួចផុតពីកាតព្វកិច្ចណាមួយ ឬ ផ្លាស់ប្តូរភាពដើមនៃកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុទេ ។ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុអាចចែងថា ភតិកៈយល់ព្រមមិនទាមទារកាត់កង ការពារ ឬ ទាមទារប្រឆាំងនឹងអ្នកដែលត្រូវបានប្រគល់សិទ្ធិ ឬ អនុប្បទានិករបស់ភតិបតីឡើយ

៨- ក្នុងករណីភតិបតីក្ស័យធន ឥណទាយករបស់ភតិបតី និងភាគីពាក់ព័ន្ធផ្សេងទៀតមិនមានសិទ្ធិច្រើនជាងសិទ្ធិដែលភតិបតីមានតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុនោះទេ ។

**ប្រការ ១០.-**

ភតិកៈមានកាតព្វកិច្ចយល់ព្រមទទួលចលនវត្ថុដែលបានជួល បើចលនវត្ថុនោះត្រូវបានប្រគល់ទាន់ពេលវេលាកំណត់ និងត្រឹមត្រូវតាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ ។ បើចលនវត្ថុដែលបានជួលមិនត្រូវបានប្រគល់ ឬ ប្រគល់យឺតពេល ឬ មិនត្រូវតាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ទេនោះ នៅពេលយល់ព្រម ឬ មុនពេលយល់ព្រម ប៉ុន្តែពុំមែនក្រោយពេលយល់ព្រមទទួលនោះទេ ភតិកៈមានសិទ្ធិបដិសេធចលនវត្ថុនោះ ហើយទាមទារឱ្យអ្នកផ្គត់ផ្គង់ជួសជុលវិការៈនោះភ្លាម ឬ រំលាយភតិសន្យាហិរញ្ញវត្ថុ ប៉ុន្តែគ្មានសិទ្ធិរំលាយ ដកហូត ឬ កែប្រែកិច្ចព្រមព្រៀងផ្គត់ផ្គង់ដោយពុំមានការយល់ព្រមពីភតិបតីឡើយ ។

ភតិបតីមានសិទ្ធិឱ្យអ្នកផ្គត់ផ្គង់ប្រគល់ចលនវត្ថុស្របតាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ តែមិនមានកាតព្វកិច្ចទទួលខុសត្រូវលើការខូចខាត ដោយសារការខកខានរបស់អ្នកផ្គត់ផ្គង់ឡើយ ។

ភតិកៈមានសិទ្ធិ និងកាតព្វកិច្ចដូចខាងក្រោម :

ក- ការយល់ព្រមទទួលចលនវត្ថុជាផ្លូវការអាចជាឯកសារ ឬ អាចតាមរយៈមធ្យោបាយផ្សេងៗទៀតដូចខាងក្រោម ÷

១- ក្រោយពេលដែលភតិកៈបានពិនិត្យចលនវត្ថុដែលត្រូវជួលនោះរួចហើយ ហើយបានបញ្ជាក់ថាអាចទទួលយកបាន ទោះបីជាចលនវត្ថុនោះស្រប ឬ មិនស្របតាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ក៏ដោយ

២- មិនបានជូនដំណឹងទាន់ពេលវេលា ដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងផ្គត់ផ្គង់ពីភាពមិនស្របតាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ទៅភតិបតី និងអ្នកផ្គត់ផ្គង់ ដើម្បីឱ្យអ្នកផ្គត់ផ្គង់ ឬ ភតិបតីអាចដោះស្រាយទាន់ពេលវេលាក្រោយពេលបានទទួលដំណឹងនោះ

៣- កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុអាចចែងថា ភតិកៈត្រូវបានចាត់ទុកថា បានយល់ព្រមទទួលចលនវត្ថុ លើកលែងតែភតិបតីបានទទួលសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធរបស់ភតិកៈ ដែលមានរាយលម្អិតពីមូលហេតុ

ច្បាស់លាស់ ក្នុងរយៈពេលកំណត់ដប់ (១០) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីភតិកៈបាន ទទួលចលនវត្ថុនោះ ។

ខ- តាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ភតិកៈមានកាតព្វកិច្ចបង់ថ្លៃឈ្នួលតាមកិច្ចព្រមព្រៀងដោយមិនអាចបដិសេធបាន នៅពេលដែលភតិកៈបានយល់ព្រមទទួលចលនវត្ថុនោះជាផ្លូវការហើយ

គ- ត្រូវប្រើប្រាស់ចលនវត្ថុឱ្យបានត្រឹមត្រូវតាមមុខសញ្ញាប្រើប្រាស់ស្របតាមច្បាប់ វិធាន និងបទបញ្ជាជាធរមាន និងតាមលក្ខណៈបច្ចេកទេស ។ ភតិកៈក៏ត្រូវចំណាយលើការថែទាំ និងជួសជុលចលនវត្ថុឱ្យនៅល្អ និងអាចប្រើប្រាស់បាន លើកលែងតែកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមានចែងផ្សេងពីនេះ

ឃ- នៅពេលផុតរយៈពេល ឬ នៅពេលរំលាយកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ និងក្នុងករណីមិនបានទិញ ឬ មិនបានជួលបន្តទេនោះ ភតិកៈត្រូវប្រគល់ចលនវត្ថុ ដែលបានជួលទៅឱ្យភតិបតីវិញ ដោយរក្សាលក្ខណៈដូចដើម លើកលែងតែការសឹករិចរិលធម្មតា

ង- ភតិកៈត្រូវទទួលខុសត្រូវចំពោះការបាត់បង់ចលនវត្ថុដែលបានជួល ចាប់ពីពេលទទួលរហូតដល់ពេលប្រគល់ចលនវត្ថុទៅភតិបតីវិញ

ច- ភតិកៈមិនត្រូវដាក់ជាអ៊ីប៉ូតែក ដាក់បញ្ចាំ ទាមទារឱ្យឃាត់ទុកចលនវត្ថុដែលបានជួល ឬ បង្កើតឱ្យមានបន្ទុកផ្សេងទៀតទៅលើចលនវត្ថុដែលបានជួលឡើយ

ឆ- ភតិកៈមានកាតព្វកិច្ចផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរទៅភតិបតី អំពីទីតាំងបច្ចុប្បន្ន និងការប្តូរទៅទីតាំងថ្មីនៃចលនវត្ថុដែលបានជួល លើកលែងតែកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមានចែងផ្សេងពីនេះ

ជ- កាតព្វកិច្ចរបស់អ្នកផ្គត់ផ្គង់តាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ ក៏ត្រូវពាក់ព័ន្ធជាមួយភតិកៈផងដែរ ប្រៀបដូចជាភតិកៈជាភាគីមួយនៃកិច្ចព្រមព្រៀងផ្គត់ផ្គង់ ហើយចលនវត្ថុដែលបានជួលហាក់ដូចជាត្រូវបានផ្គត់ផ្គង់ផ្ទាល់ទៅឱ្យភតិកៈ ។ ប៉ុន្តែ អ្នកផ្គត់ផ្គង់មិនទទួលខុសត្រូវលើវិការៈមួយចំពោះភតិកៈផង និងភតិបតីផងនោះទេ ។ សិទ្ធិរបស់ភតិកៈនៅក្នុងកិច្ចព្រមព្រៀងផ្គត់ផ្គង់ដែលភតិកៈបានយល់ព្រមហើយ មិនត្រូវបានប៉ះពាល់ដោយសារតែការកែប្រែលក្ខខណ្ឌណាមួយនៃកិច្ចព្រមព្រៀងផ្គត់ផ្គង់ទេ លើកលែងតែភតិកៈបានយល់ព្រមលើការកែប្រែនោះ

ឈ- មិនត្រូវជួលបន្ត ចាត់ចែង ឬ ផ្ទេរសិទ្ធិកាន់កាប់ ឬ ប្រើប្រាស់ចលនវត្ថុដែលបានជួល ឬ សិទ្ធិណាមួយផ្សេងទៀតក្រោមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីភតិបតី និងមិនត្រូវចំណុះសិទ្ធិរបស់តតិយភាគីឡើយ ។ ការជួលបន្ត ការចាត់ចែង ឬ ការផ្ទេរ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីភតិបតីត្រូវចាត់ទុកជាមោឃៈ ។

**ប្រការ ១១.-**

ធនាគារជាតិនៃកម្ពុជា មានសិទ្ធិបញ្ឈប់ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ក្នុងករណីដែល :

- ធនាគារមិនគោរពតាមច្បាប់ បទប្បញ្ញត្តិ និងលក្ខខណ្ឌផ្សេងៗ ដែលមានចែងនៅក្នុងប្រកាសនេះ
- ធនាគារមិនអនុវត្តតាមផែនការអាជីវកម្មរបស់ខ្លួន
- ក្នុងករណីផ្សេងទៀតដែលធនាគារជាតិនៃកម្ពុជាយល់ឃើញថា មានផលប៉ះពាល់ដល់ផលប្រយោជន៍ សន្តិសុខ ឬ សុវត្ថិភាពសាធារណៈ ។

**ប្រការ ១២.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន ធនាគារ គ្រប់នាយកដ្ឋាន អង្គភាព នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ១៣.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

ភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៨

ទេសាភិបាល

ជា-ចាន់តូ

<u>កន្លែងទទួល</u> :

- ដូចប្រការ ១២ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ និងឯកសារ

<u>ចម្លងជូន</u> :

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជូនជ្រាបជាព័ត៌មាន"

- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number B7.08.088 Prakor.

**Unofficial translation**

# Prakas

**on**

## Financial Lease

**The Governor of the National Bank of Cambodia,**

- With reference to the Constitution of the Kingdom of Cambodia,
- With reference to the Royal Kram NS/RKM/ 0196/27 of January 26, 1996 promulgating the Law on the Organization and Conduct of the National Bank of Cambodia,
- With reference to the Royal Kram NS/RKM/1199/13 of November 18,1999 promulgating the Law on Banking and Financial Institutions,
- With reference to the Royal Decree NS/RKT/0508/526 of May 13, 2008 on the reappointment of His Excellency Chea Chanto as Governor General of the National Bank of Cambodia, equivalent to Senior Minister,
- Pursuant to the recommendation made by National Bank of Cambodia management during the May 21, 2008, meeting.

**DECIDES**

**Article 1.-**

To authorize commercial banks and specialized banks, hereinafter referred to as "the bank" to conduct financial leasing business according to article 2.1 of the Law on Banking and Financial Institutions.

**Article 2.-**

The bank must have policies and procedures for conducting leasing business, and have appropriate operational systems, risk management systems, and internal control systems.

**Article 3.-**

For the purpose of this Prakas, the terms shall be defined as follows:

- ***Lessor*** a person, natural or legal, who transfers the right of possession and use of movable property to a lessee.

- ***Lessee*** a person, natural or legal, who receives the right of possession and use of movable property from a lessor.

- ***Movable property*** all properties, plants, and equipment except land and buildings.

- ***Term*** the period of time specified in the lease agreement in which the lessee is allowed the possession and use of the leased movable property.

- ***Lease*** a transaction in which a lessor enters into an agreement with a lessee in which the lessee is granted the right to possession and use of movable property for a term in return for periodic lease payments or their equivalent. "Lease" shall include a sub-lease.

- ***Sub-lease*** a transaction in which leased property is re-leased by the original lessee to other parties, and the lease agreement between the original parties remains in effect.

- ***Financial lease*** a lease for an initial non-cancelable term of a year or more, in which:

  i- the lessee specifies the movable property and selects the supplier without relying primarily on the skill and judgment of the lessor; and

  ii- the movable property is acquired by the lessor in connection with a financial lease agreement for leasing to the lessee.

  Provided, however, that a subsequent lease of previously leased movable property is from the same lessor, such a lease can still qualify as a financial lease.

  A lease may be a financial lease without regard to:

  i- whether or not the periodic lease payments are calculated so as to take into account the amortization of the whole or a substantial part of the cost of the movable property, or

  ii- whether or not the lessee has or subsequently acquires the option to buy the movable property or hold it on lease for a further period.

- ***Advance lease payment*** any number of periodic lease payments that are paid by the lessee at or before the inception of the lease. Advance lease payments are not a security deposit.

- ***Security deposit*** an amount identified in a lease agreement as an amount paid by the Lessee and to be held by the Lessor as security for the full and regular obligations by the Lessee under the Lease Agreement.

- ***Supplier*** a person, natural or legal, from whom a lessor acquires movable property to be leased to a lessee. The lessor's acquisition could be by purchase, lease, and assignment of a right to purchase or lease, including assignment of right from the lessee. The lessee could be a supplier in a sale-leaseback transaction.

- ***Supply agreement*** the agreement by which the lessor acquires possession and use of the movable property to be leased to the lessee.

- ***Financial lease agreement*** an agreement in which the lessor purchases movable property selected by the lessee from the supplier, leases this movable property to the lessee and authorizes the lessee to periodically pay the lease payment.

**Article 4.-**

Financial leases which do not meet the definition in article 3 of this Prakas will continue to be treated as a traditional rental, hire or operational lease that does not fall under the definition of banking operations.

**Article 5.-**

Banks are allowed to do all sorts of leasing, including financial and operational leasing, whereas non-banks are prohibited from doing financial leases on a regular basis.

**Article 6.-**

Banks who wish to conduct financial leases shall:
(a) have good financial conditions and operating performance, a good solvency ratio, and hold other financial ratios in compliance with the regulations of the National Bank of Cambodia.
(b) have a written business plan for the financial lease approved by the board of directors of the bank. Such a plan shall include the following contents:
(i) policy and procedure for business operations
(ii) details of the risk management system, internal control system, and accounting system. The details of the risk management system shall at the very least include:
- the credit analysis system, procedures in setting customer's line of credit, procedures in setting security deposit and other fee.
- procedures in property management, including the acquisition of movable property, management of confiscated movable property, the monitoring and inspection of movable property, the valuation of movable property, and the valuation of residual value of movable property.

(c) obtain prior approval from the National Bank of Cambodia.

**Article 7.-**

Banks shall have at least two written financial lease agreements with their clients whereby all related parties shall agree upon and abide by the terms and conditions as

specified in the present Prakas. The agreement shall have at least two copies, one of which shall be given to the lessee. The financial lease agreement shall mention, at the very least, the following important points:

(a) a description of the leased movable property;
(b) the amount, periodicity, and duration of the financial lease payments;
(c) the commencement date of the financial lease and;
(d) the signature of the lessor and the lessee.

**Article 8.-**

In cases where the agreement has been terminated and movable property is confiscated from the lessee, the bank shall sell or re-lease the movable property within three months from the termination date or confiscating date. If, after such period, the bank cannot sell or re-lease that property, the bank shall classify and make provisions for that movable property according to the Prakas on Loans Classification, Provisioning and Advance of Banks and Financial Institutions.

**Article 9.-**

The ownership right to the leased movable property shall remain with the lessor at all times during the lease term, and thereafter, until transferred to the lessee or other parties. The lessor has the follwing rights and obligations:

(a) shall be responsible for all import duties and fiscal obligation stated by law and for registration fees upon the leased movable property, unless the lease agreement provides otherwise.
(b) has an obligation to pay for the movable property to the supplier once the lessee has accepted it without condition or reservation.
(c) warrants the quiet use and possession of the leased movable property to the lessee for the lease term to be free from interference, provided that the lessee is not in breach of the lease agreement.
(d) shall not be liable to the lessee in respect of the movable property except to the extent that the lessee has suffered losses as a result of the lessor's intervention in the selection of the movable property or in the specification of the movable property.
(e) during the implementation of the financial lease agreement, the lessor shall not be liable for any damages to third parties caused by the lessee using the leased movable property.
(f) in the event of a default of the financial lease agreement by the lessee, the lessor shall have in addition to such rights as provided by the lease agreement, the following rights.-

    (i) may require the lessee to pay the accrued unpaid lease payments together with interest and damages.

    (ii) may also require accelerated payments of the future lease payments, may terminate the lease agreement, and may recover possession of the leased movable property if:
    - the lessee does not pay the lease payments pursuant to the lease agreement for two consecutive lease payment periods;

- the lessee breaches any other provision of the lease agreement and fails after receiving written notice from the lessor to remedy such breach within ten (10) days;
- the lessee has a guarantor who is insolvent, bankrupt, or dissolved and the lessee has failed to find a substitute guarantor acceptable to the lessor within thirty (30) days of a written demand by the lessor to do so; or
- the lessee is insolvent, bankrupt, dissolved or dead without assignee.

(iii) Whether or not the lease agreement is terminated prior to its expiration, the lessor may.-
- recover possession of the leased movable property without having to go to court if such action would not cause a breach of the peace; and
- recover such damages as acceptable by the lessor, including the additional costs caused by the default of the lessee; the lease agreement may provide for the manner in which such damages are to be computed and such computation shall be enforceable by the two parties unless it would result in damages substantially in excess of those which will place the lessor in the position in which it would have been had the lessee performed the lease agreement in accordance with its terms.

(iv) If necessary, the lessor may request a court order directing the lessee to immediately return the movable property to the lessor upon presentation of an affidavit stating that the lessee is in default of the lease agreement. But the lessor shall remain liable for any damages caused to the lessee if it is subsequently proven that repossession was a breach of the lease agreement by the lessor.

(g) has the right to require that the lessee indemnify the lessor from any and all losses, claims, damages or other consequences arising from or in connection with the lessee's use and possession of the leased movable property.

(h) may require that the lessee obtain, maintain and pay for liability and casualty insurance covering the leased movable property during all times that s/he is in the possession or control of the lessee until the leased movable property has been returned to the possession and control of the lessor, even if the lease term has come to an end or the lease agreement had been terminated at an earlier time. If the lessee is obligated to obtain and pay for insurance, and fails to do so, the lessor has the right, but not the duty, to obtain such insurance and the lessee shall immediately reimburse the lessor if s/he has incurred such a cost.

(i) The leased movable property shall not be part of the lessee's estate. In this regard, in the case of bankruptcy of the lessee, all creditors of the lessee, including those who obtained the right to foreclose the lessee's property by court decision, shall have no right in the case of the leased movable property.

(j) may assign, transfer or otherwise deal with any or all of its rights in the leased movable property or under the lease agreement to any parties without the consent of the lessee. Such a transfer shall not relieve the lessor of any of her/his obligations or alter the nature of the lease agreement. The lease agreement may provide that lessee not agree to assert any offsets, defenses or claims against any assignee or transferee of lessor.

(k) In the case of lessor bankruptcy, the lessor's creditors and other interested parties shall have no greater rights than the lessor has pursuant to such financial lease agreements.

**Article 10.-**

A lessee has the obligation to accept the leased movable property if it is delivered in a timely fashion and conforms to the supply agreement. If the leased movable property is not delivered or is delivered late or does not conform to the supply agreement, then at or before the time for acceptance, but not after, the lessee has the right to reject the movable property, demand from the supplier the immediate cure of its defect or defects, or cancel the lease agreement, but shall have no right to terminate, rescind or modify the supply agreement without the consent of the lessor.

The lessor has the right to ask the supplier to supply the movable property in conformity with the supply agreement but he has no obligation to be responsible for the failure caused by the supplier.

The lessee has the followings rights and obligations:

(a) acceptance of the movable property may be made by making a document acknowledging acceptance, or by other means which include:
   (i) lessee by its actions with respect to the leased movable properties has indicated that the movable property is acceptable, whether within compliance with the supply agreement or without;
   (ii) lessee has failed to give timely notice as specified in the supply agreement to lessor and supplier of specific non-compliance with the supply agreement, where the supplier or lessor could have conveniently solved the non-compliance had they been given timely notice;
   (iii) The lease agreement may provide that the lessee shall be deemed to have accepted the movable property unless the lessor receives a written notice of the lessee's rejection, detailing the specific reasons for rejection, within a specified period of ten (10) business days after the lessee has received the movable property.

(b) the lessee's obligations under a financial lease, including the obligation to pay the lease payment, become absolute and irrevocable upon the lessee's acceptance of the movable property.

(c) shall use the movable property in a reasonable manner in accord with its movable properties and purpose, and in compliance with all applicable laws, rules and regulations, operational manuals, and manufacturer requirements. Lessee shall also at its own expense maintain and repair the movable property and keep it in good condition and usable unless the lease agreement provides otherwise.

(d) at the expiration of the lease term or upon termination of the lease agreement, and in the absence of the proper exercise of any purchase option or renewal option, lessee shall return the leased movable property to lessor in as good a condition as originally delivered, except for normal wear and tear.

(e) shall bear all risk of loss respecting the leased movable property from the time of its delivery until it is returned to the lessor.

(f) The lessee shall not mortgage, pledge, encumber, lien or otherwise create a charge over the leased movable property.

(g) lessee is obligated to keep lessor informed in writing as to the current and the removal to a new location of the leased movable property unless the lease agreement provides otherwise.

(h) the obligations of the supplier under the supply agreement shall also be owed to the lessee as if it were a party to the supply agreement and as if the leased movable property were to be supplied directly to the lessee. However, the supplier shall not be liable to both the lessor and the lessee in respect to the same damage. The lessee's rights derived from the supply agreement shall not be affected by a variation of any term of the supply agreement previously approved by the lessee unless s/he consented to that variation.

(i) may not sublease, assign or transfer the right to the possession or use of the leased movable property under the lease agreement or in the leased movable property without the prior written consent of the lessor and subject to the rights of third parties. Any such attempted sublease, assignment or transfer without lessor's prior written consent shall be null and void.

**Article 11.-**

The National Bank of Cambodia has the authority to stop the leasing business operation in the following cases:

- the bank does not comply with the rules and conditions as specified in the Prakas.
- the bank does not act in accordance with its own business plan.
- other cases in which the National Bank of Cambodia considers public security and interest threatened.

**Article 12.-**

The General Direction, the General Secretariat, the General Inspection, the General Cashier, banks, all Departments of the National Bank of Cambodia and under the National Bank of Cambodia's supervisory authority shall strictly implement this Prakas.

**Article 13.-**

This Prakas shall take effect from the signing date.

Phnom Penh, May 30, 2008

**The Governor,**

**Signed : Chea Chanto**

cc:
- The Members of the Board of Directors
- The parties concerned as stated in Article 12
- File
- CM "for info"
- Administration Department of CM
  "for publication in the National Gazette".